**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**
**អង្គភាពថវិកាមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ**
**ក្រុមលទ្ធកម្មមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ**
លេខ : ..................ម.អ.ជ .ខសន/កល

[illegible]ត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## អញ្ជើញចូលរួមដេញថ្លៃការងារជួសជុល ផ្លូវក្រាលគ្រួសក្រហម ប្រវែង ៣ ៤៥៥ម ទទឹង ៤ម ស្ថិតក្នុងឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ សម្រាប់ឆ្នាំ ២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ

អង្គភាពថវិកាមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា អង្គភាពថវិកាមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការ **ការងារជួសជុល ផ្លូវក្រាលគ្រួសក្រហមប្រវែង ៣ ៤៥៥ម ទទឹង ៤ម ឆ្នាំ ២០១៧។**

អង្គភាពថវិកាមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅក្រុមលទ្ធកម្មមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុដែលមានអាសយដ្ឋាននៅភូមិលេខ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនង: ០១៦ ៩៧៤ ៩៤៧/ ០១៥ ៦៥៥ ៣៣៣) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង១០:០០នាទីដោយភ្ជាប់មក ជាមួយនូវឯកសារក្រុមហ៊ុន ( Profile Company) ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង១០:០០នាទីព្រឹក ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ចម្លងជូន ៖**
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
( អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ )
-ក្រសួងអភិវឌ្ឍន៍ជនបទ
« ដើម្បីគោរពជូនជ្រាប »
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

ខេត្តព្រះសីហនុ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧
**ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ**
**និងជាប្រធានក្រុមលទ្ធកម្ម**

ដេញថ្លៃ សំណង់ ទំព័រ 3

ដេន.ម៉ាលស័យ